អង្គការអនុផលព្រៃឈើ
Non-Timber Forest Products

# ដំណឹងជ្រើសរើសបុគ្គលិក

## តួនាទី: បុគ្គលិកមូលដ្ឋានផ្នែកសម្របសម្រួលការងារអប់រំនៃគម្រោងPLE នៅខេត្តស្ទឹងត្រែង

អង្គការអនុផលព្រៃឈើគឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលមានទីតាំងនៅក្នុងខេត្តរតនគិរីនិងមានសាខានៅខេត្តព្រះវិហារនិងខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា។អង្គការNTFP បានដើរតួយ៉ាងសំខាន់តាំងពីឆ្នាំ១៩៩៦នៅក្នុងការស្វែងរកការគាំទ្រសំរាប់សិទ្ធិជនជាតិដើមភាគតិចនិងសិទ្ធិកាន់កាប់គ្រប់គ្រងធនធានធម្មជាតិ។ NTFPបានរកឃើញបញ្ហាស្នូលនៃច្រកចូលប្រកបដោយសុវត្ថិភាពក្នុងការគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិជាមួយនឹងសកម្មភាពដំបូងរួមមានសហគមន៍ព្រៃឈើ សិទ្ធិកាន់កាប់ដីធ្លី ការគ្រប់គ្រងតំបន់ការពារដោយមានការចូលរួម ការស្វែងរកការគាំទ្រ អប់រំក្រៅប្រព័ន្ធ និងបង្កើនជីវភាពរស់នៅសំរាប់សហគមន៍ជនជាតិដើមភាគតិច។

## អង្គការNTFPត្រូវការជ្រើសរើស បុគ្គលិកមូលដ្ឋាន ចំនួន ១ រូប

☞ **តួនាទី ៖ បុគ្គលិកមូលដ្ឋានផ្នែកសម្របសម្រួលការងារអប់រំនៃគម្រោងPLE**

☞ **ទីតាំងការងារ ៖ ខេត្តស្ទឹងត្រែង ក្នុង ស្រុកសេសាន និង ស្រុកសៀមប៉ាង**

### តំរូវការ:

- បេក្ខជន រឺ បេក្ខនារីដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ (ស្រ្តីត្រូវបានលើកទឹកចិត្តនិងផ្តល់អាទិភាពខ្ពស់)។
- អាចទៅធ្វើការនិងស្នាក់នៅក្នុងភូមិគោលដៅ(ចំណាយពេល៨០%ជាមួយសហគមន៍គោលដៅ)
- មានបទពិសោធន៍ធ្វើការងារអភិវឌ្ឍន៍យ៉ាងតិច២ឆ្នាំ។
- ចេះប្រើប្រាស់ម៉ូតូនិងថែទាំសម្ភារ:របស់អង្គការ។
- មានជំនាញកុំព្យូទ័រ (Microsoft Word, Excel, Power Point, Email, និង Internet)។
- អាចអាននិងសរសេរភាសាអង់គ្លេសបានកាន់តែប្រសើរ។
- មានការទទួលខុសត្រូវខ្ពស់និងស្មោះត្រង់។
- មានការតាំងចិត្តក្នុងការបំពេញការងារនិងបទបែនតាមការលះ:ទេស:។

**ការទទួលខុសត្រូវរួម**

- រៀបចំផែនការសកម្មភាព ផែនការថវិកាប្រចាំខែ,ប្រចាំត្រីមាសនិងប្រចាំឆ្នាំ
- សរសេររបាយការណ៍រីកចំរើន ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងបញ្ជូនទៅស្ថាប័ន ពាក់ព័ន្ធ ។
- ធ្វើករណីសិក្សានិងរបាយការណ៍ករណីសិក្សា
- សិក្សាព័ត៌មានបឋម និងត្រួតពិនិត្យវាយតំលៃតំរោង
- តាមដាន ត្រួតពិនិត្យ វាយតំលៃ សកម្មភាពនិងលទ្ធផលគម្រោង ហើយរក្សាទុកដាក់ឯកសាររបាយការណ៍។
- ចូលរួមប្រជុំសមាហរណកម្មផែនការឃុំ ស្រុក ខេត្ត
- ធានាថាថវិការបស់គម្រោង ត្រូវបានចំណាយយ៉ាងមានប្រសិទ្ធិភាពប្រសិទ្ធិផល និងមានតម្លាភាព។
- ចូលរួមត្រួតពិនិត្យថវិកាគម្រោងជាប្រចាំជាមួយមន្ត្រីគម្រោង។
- កសាងឯកសារសំណុំបែបបទគម្រោងនិងចងក្រងរក្សាឯកសារលទ្ធផលនានារបស់គម្រោង។
- វាយការណ៍ជាប្រចាំពីបញ្ហា និងវឌ្ឍនះភាពរបស់គម្រោង
- រៀបចំសិក្ខាសាលា វេទិកា ឬប្រជុំផ្សេងៗ។
- ត្រូវគោរពតាមគោលនយោបាយដូចជាគោលនយោបាយការពារកុមារ , គោលនយោបាយប្រឆាំងអំពើពុករលួយ,គោលនយោបាយហិរញ្ញវត្ថុ,គោលនយោបាយធនធានមនុស្ស គោលនយោបាយរដ្ឋបាល។ល។

**គុណសម្បត្តិ និងបទពិសោធន៍ការងារ**

- កំរិតវប្បធម៍ថ្នាក់មធ្យមសិក្សាបឋមភូមិ ប្រហាក់ប្រហែល។
- បទពិសោធន៍ការងារចាប់ពី 2ឆ្នាំឡើងទៅ។

អង្គការNTFPផ្តល់ឱកាសស្មើៗគ្នាក្នុងគោលការណ៍អភិវឌ្ឍន៍ លើកកម្ពស់ជនជាតិដើមភាគតិច និងគុណភាពយេនឌ័រនៅក្នុងអង្គការ។

សម្រាប់តួនាទី**<u>បុគ្គលិកមូលដ្ឋាននៃគម្រោងPLE</u>**នឹងទទួលបានប្រាក់បៀវត្សចំនួន**<u>៣០០ដុល្លារ</u>** ក្នុងមួយខែ និងប្រាក់ឧបត្ថម្ភចំនួន**<u>១៥ដុល្លារ</u>** សម្រាប់ការថែទាំសុខភាពប្រចាំខែ និងការឧបត្ថម្ភផ្សេងៗទៀតដែលមានចែងនៅក្នុងគោលនយោបាយរបស់អង្គការNTFP។

បេក្ខជនបេក្ខនារីដែលមានចំណាប់អារម្មណ៍សូមផ្ញើប្រវត្តិរូបសង្ខេបCVនិងលិខិតអម **តាមរយៈ**:<u>អ៊ីម៉ែល phosamnang86@gmail.com;adhr.ntfp@gmail.com</u> ឬ***<u>ទំនាក់ទំនងតាមទូរស័ព្ទលេខ:</u> 089 98 35 91***។

*បញ្ជាក់៖ NTFP មិនមានពាក្យសម្រាប់អោយបំពេញទេ ដូចនេះ បេក្ខជន ឬបេក្ខនារី ត្រូវបំពេញពាក្យដោយខ្លួនឯង។*

***ឈប់ទទួលពាក្យនៅ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២២ វេលាម៉ោង 5:00 ល្ងាច។***